វ៉ុល០១ | លេខ០៣ | ខែមីនា ឆ្នាំ២០២២
VOLUME 01 | ISSUE 03 | MARCH 2022

# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTRADE BULLETIN

## INSIDE

Infographic
Local | Global News
Policy Brief

# ៤ ចំណុចសំខាន់ដែលសាធារណជនត្រូវដឹងពី អាសិប



**អាសិប** គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីធំជាងគេបង្អស់ មានសមាជិកចំនួន **១៥ ប្រទេស** រួមមានសមាជិក **អាស៊ានទាំង ១០ ប្រទេស** និងប្រទេសដៃគូពាណិជ្ជកម្មអាស៊ានចំនួន **៥** រួមមាន អូស្ត្រាលី នូវែលសេឡង់ ចិន ជប៉ុន និងកូរ៉េខាងត្បូង។




**២,០-៣,៩%** រំពឹងនឹងកើនលើចំណូលពន្ធ

**៣,២-៦,២%** រំពឹងនឹងកើនលើចំនួនការងារ

**៩,៤-១៨%** រំពឹងនឹងកើនលើការនាំចេញ (កម្មន្តសាល និងសេវាកម្ម)

**២-៣,៨%** រំពឹងនឹងកើនលើកំណើនសេដ្ឋកិច្ច

**ប្រភព៖** Regional Comprehensive Economic Partnership: Implications, Challenges, and Future Groth of East Asia and ASEAN (2022)

សូមស្កេនទីនេះដើម្បីទាញយកឯកសារ៖

សៀវភៅអាសិប

ព្រឹត្តិបត្រពាណិជ្ជកម្ម វ៉ុល០១ លេខ ០៣

រៀបចំដោយ៖

## ១. សេរីភាវូបនីយកម្មពាណិជ្ជកម្ម

- បន្ថយអត្រាពន្ធគយ
- កាត់បន្ថយវិធានការមិនមែនពន្ធគយ (NTMs Checklist)
- សុខដុមនីយកម្មនៃវិធានដើមកំណើតទំនិញ

**កាត់បន្ថយថ្លៃធ្វើពាណិជ្ជកម្ម**

១. តំលៃឯកតានៃការនាំចូលកាន់តែថោកជាងមុន
២. បង្កើនភាពប្រកួតប្រជែងសម្រាប់ផលិតកម្មក្នុងស្រុក (ដែលប្រើប្រាស់វត្ថុធាតុនាំចូល)
៣. ផលិតកម្មកើនឡើង និងបង្កើនទំហំពាណិជ្ជកម្ម និង
៤. ជំរុញកំណើនសេដ្ឋកិច្ចក្នុងតំបន់អាសិបកាន់តែរហ័ស។

## ២. កំណើនចំណូលពិតប្រាកដសម្រាប់កម្ពុជា

### រូបទី១៖ ប្រទេសកម្ពុជា

កំណើនចំណូលពិតប្រាកដនៅក្នុងកិច្ចព្រមព្រៀងអាសិប
បម្លាស់ប្តូរជាភាគរយធៀបទៅនឹងសេណារីយ៉ូដែលមិនមានកិច្ចព្រមព្រៀងអាសិបឆ្នាំ២០៣៥




**១+%** កំណើនចំណូលពិតប្រាកដ ជាមួយសេរីភាវូបនីយកម្មវិធានដើមកំណើតទំនិញ*

* សំដៅដល់ការអនុវត្តវិធានដើមកំណើទំនិញរួមគ្នាក្នុងចំណោមសមាជិក

vs

**៣+%** កំណើនចំណូលពិតប្រាកដ ជាមួយកំណើនប្រសិទ្ធិភាពផលិតកម្ម*

* សេណារីយ៉ូសន្មតដែលសេរីភាវូបនីយកម្មពាណិជ្ជកម្មនាំមកនូវកំណើនប្រសិទ្ធិភាពផលិតកម្ម

នៅពេលដែលកំណើនប្រសិទ្ធិភាពផលិតកម្មត្រូវបានរាប់បញ្ចូល កម្ពុជា **ជាប់លេខរៀងទី៣** ដែលទទួលបានអត្ថប្រយោជន៍នៃការកើនចំណូលពិតប្រាកដច្រើនជាងគេក្នុងចំណោមសមាជិកទាំងអស់ នៅពីក្រោយប្រទេសវៀតណាម និងម៉ាឡេស៊ី។

**ប្រភព៖** អត្ថបទស្រាវជ្រាវរបស់ធនាគារពិភពលោក (២០២២)

## ៣. ការអនុគ្រោះវិធានដើមកំណើតទំនិញ

**វិធានដើមកំណើតទំនិញ** តែមួយក្នុងអាសិប
**អាចកាត់បន្ថយថ្លៃធ្វើពាណិជ្ជកម្ម**
**និងអាចជំរុញពាណិជ្ជកម្មតំបន់បានយ៉ាងធំធេង**




## ៤. សមាហរណកម្មអាស៊ាន និងតំបន់

**អាសិប** មានធាតុសំខាន់ៗដែលអាចពង្រឹង
**សមាហរណកម្មអាស៊ាន និងតំបន់អាស៊ីបូព៌ា**

- ពាណិជ្ជកម្ម និងវិនិយោគផ្អែកលើច្បាប់
- ច្រកទីផ្សារ
- កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច
- មជ្ឈភាពអាស៊ាន
- កិច្ចព្រមព្រៀងដែលអាចពិភាក្សាបន្ត ('LIVING' AGREEMENT)

**អាសិប** →
**ការស្តារសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩**
**ខ្សែច្រវ៉ាក់តម្លៃសកលប្រកបដោយបរិយាប័ន្ន និងចីរភាព**

ធាតុទាំងនេះមានសារៈសំខាន់សម្រាប់ការស្តារសេដ្ឋកិច្ចនៃតំបន់អាស៊ាន និងអាស៊ីបូព៌ា ក្រោយស្ថានការណ៍កូវីដ-១៩ និងសម្រាប់ឈានទៅរកដំណាក់កាលបន្ទាប់ដើម្បីសម្រេចបាននូវការលូតលាស់ប្រកបដោយបរិយាប័ន្ន និងចីរភាពនៅក្នុងសមាហរណកម្មតំបន់ និងក្នុងខ្សែច្រវ៉ាក់តម្លៃសកល។

# 4 KEY FACTS PUBLIC NEEDS TO KNOW ABOUT RCEP



**RCEP** is the world's largest free trade agreement, constituting **15** member countries including **10** ASEAN Member Countries and **5** trading partners of ASEAN: Australia, New Zealand, China, Japan and South Korea.




**2.0 - 3.9%** expected increase in tax revenue

**3.2% - 6.2%** expected employment growth

**9.4 - 18%** expected increase in export (Manufacturing and Service)

**2 - 3.8%** expected GDP growth

**Source:** Regional Comprehensive Economic Partnership: Implications, Challenges, and Future Growth of East Asia and ASEAN (2022)

Please scan the following documents:

RCEP: Implications, Challenges and Future Growth of East Asia and ASEAN

iTrade Bulletin Vol 01 Issue 03

Organized By:

## 1. Trade liberalization

Tariff reduction

NTMs Checklist

Non-tariff measures reduction

Harmonization of Rule of Origin (ROO)

**Reduction of Trade Costs**

1. Price of a unit of imports is less expensive,
2. Increase the competitiveness of local production (using imported inputs),
3. Productivity gains & expansions of trade, and
4. Faster economic growth in the RCEP region.

## 2. Real Income Gains by Cambodia

**Figure1: Cambodia**

Real income gains in RCEP:
Percentage change relative to business-as-usual scenario, 2035




**1+%** Real income gain with **Roo liberalization**.
* Implementation of a common set of rules or origins.

VS

**3+%** Real income gain with **productivity gains**.
* Studied assumption that trade liberalization leads to an increase in productivity

When the productivity gains are assumed, Cambodia is in the **top 3rd** to benefit the most in terms of real income, behind Vietnam and Malaysia.

Source: World Bank Group (2022), Estimating the Economicand Distributional Impacts of the Regional ComprehensiveEconomic Partnership

## 3. Preferential Rule of Origin

Single **Rule of Origin** in RCEP
**could reduce substantial trade costs**
**and boost regional trade significantly.**




## 4. ASEAN and Regional Integration

**RCEP** has key features that could strengthen
**Integration of ASEAN and East Asian Region**

Rule-based trade and investment

Market Access

Economic Cooperation

ASEAN Centrality

'Living' Agreement

**RCEP** → **Post-Covid recovery** / **Inclusive & sustainable GVCs**

These elements are significant for the recovery of East Asia and ASEAN in the post-pandemic period and for moving the region to the next stage of inclusive and sustainable growth in regionalism and GVCs.

ព្រឹត្តិបត្រពាណិជ្ជកម្ម
iTRADE BULLETIN
វ៉ុល០១ | លេខ០៣ | ខែមីនា ឆ្នាំ២០២២
VOLUME 01 | ISSUE 03 | MARCH 2022

# ព័ត៌មានក្នុងស្រុក

## សម្តេច ហ៊ុន សែន និងនាយករដ្ឋមន្ត្រីជប៉ុន ពិភាក្សាពី លទ្ធភាពបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ការវិនិយោគប្រមូលផ្តុំ និងការនាំចេញផលិតផលកសិកម្ម[1]

ប្រភព៖ Phnom Penh Post

ក្នុងអំឡុងពេលពីរថ្ងៃ នៃការធ្វើទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីជប៉ុនមកកម្ពុជាកាលពីថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០២២ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានស្នើទៅឯកឧត្តម ហ្វូមីអុ គីហ្ស៊ីដា នាយករដ្ឋមន្ត្រីជប៉ុន ដើម្បីពិចារណាពីលទ្ធភាពក្នុងការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ជំរុញអ្នកនាំចូលឱ្យទិញផលិតផលកសិកម្មអាទិភាពកម្ពុជាកាន់តែច្រើន និងលើកទឹកចិត្តក្រុមហ៊ុនជប៉ុនធំៗ ឱ្យមកវិនិយោគនៅកម្ពុជា។ នេះ គឺជាកិច្ចប្រឹងប្រែងរបស់សម្តេចនាយករដ្ឋមន្ត្រីក្នុងការពង្រីកពាណិជ្ជកម្មទ្វេភាគី និងពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចបន្ថែមទៀតជាមួយជប៉ុន ព្រមទាំងជានាការវិនិយោគជប៉ុនធំៗនៅកម្ពុជា។ លើសពីនេះ ភាគីទាំងពីរ ក៏បានយល់ព្រមលើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្រទ្វេភាគីឱ្យកាន់តែប្រសើរឡើងតាមបរិបទថ្មី ដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុង វិស័យសំខាន់ៗមួយចំនួនដូចជា កម្មន្តសាល ថាមពល ទេសចរណ៍ និងវិស័យសេដ្ឋកិច្ចផ្សេងទៀតដូចជា សន្តិសុខ បណ្តាញទូរគមនាគមន៍ និងការផ្លាស់ប្តូរបញ្ញាវន្ត។ ភាគីទាំងពីរ ក៏យល់ព្រមសហការធ្វើឱ្យកំពង់ផែស្វយ័តព្រះសីហនុក្លាយទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិដ៏សំខាន់។ ចុចទីនេះដើម្បីអានបន្ថែម

## ក្រសួងពាណិជ្ជកម្មកម្ពុជា ឈានទៅបញ្ចប់សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរមា ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

ប្រភព៖ ក្រសួងពាណិជ្ជកម្ម

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា បានដឹកនាំកិច្ចប្រជុំបច្ចេកទេសដើម្បីពិនិត្យ និងពិភាក្សាចុងក្រោយលើ សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) មុននឹងបញ្ជូនទៅក្រសួងចំនួន ១៥ ផ្សេងទៀត ដើម្បីពិនិត្យ និងអនុម័តចុងក្រោយ។ ឯកឧត្តមរដ្ឋមន្ត្រីមានប្រសាសន៍ថា សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើង ដើម្បីកំណត់ផលិតផលសក្តានុពល ដែលជាឧត្តមភាពរបស់កម្ពុជា ដែលត្រៀមនឹងទទួលបានការអនុគ្រោះពន្ធគយ ក្រោម FTAs ដែលមានស្រាប់។ ផលិតផលសក្តានុពលទាំង ១០ ដែលត្រូវបានកំណត់ រួមមាន អង្ករ ដំឡូងមី ចេកមៀនប៉ៃលិន ស្វាយ ស្វាយចន្ទី សាច់ កៅស៊ូធម្មជាតិ ម្នាស់ និងម្រេច។ លើសពីនេះ ឯកសារយុទ្ធសាស្ត្រនេះ ក៏នឹងកំណត់បញ្ហាប្រឈមនានា អមដោយដំណោះស្រាយ ដែលសមស្របនឹងបរិបទអភិវឌ្ឍន៍របស់កម្ពុជា។ ខណៈដែលកិច្ចព្រមព្រៀង CCFTA, RCEP, និង CKFTA ត្រូវបានផ្តល់សច្ចាប័នរួចហើយ យុទ្ធសាស្ត្រនេះនឹងដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់អត្ថប្រយោជន៍របស់កម្ពុជា ពីកិច្ចព្រមព្រៀងខាងលើ និងផ្សេងទៀត។ ចុចទីនេះដើម្បីអានបន្ថែម

---

[1] បកប្រែក្រៅផ្លូវការ

## កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) នឹងជួយជំរុញការនាំចេញរបស់កម្ពុជាពី ៩ ដល់ ១៨% ក្នុងមួយឆ្នាំ[2]

ប្រភព៖ Khmer Times

ថ្លែងក្នុងសិក្ខាសាលាស្តីពី "ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)៖ ផលបច្ច័យ បញ្ហាប្រឈម និងកំណើនសេដ្ឋកិច្ចនាពេលអនាគតសម្រាប់តំបន់អាស៊ីបូព៌ា និងអាស៊ាន" កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា បានបញ្ជាក់ថា ការសិក្សាចុងក្រោយរបស់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) បង្ហាញថា ការនាំចេញរបស់កម្ពុជាត្រូវបានរំពឹងថា នឹងកើនឡើងយ៉ាងហោចណាស់ ៩,៤% ក្នុងមួយឆ្នាំ ក្រោមកិច្ចព្រមព្រៀង RCEP។

ឯកឧត្តមបានបញ្ជាក់ថា តួលេខកើនឡើងនេះត្រូវបានកែសម្រួលពីតួលេខ ៧,២% ដែលធ្វើឡើងក្នុងឆ្នាំ ២០១៤ ដោយ ERIA។ ឯកឧត្តមរដ្ឋមន្ត្រីមានប្រសាសន៍ថា "ក្រោមកិច្ចព្រមព្រៀង RCEP កម្ពុជានឹងឃើញកំណើនការនាំចេញក្នុងមួយឆ្នាំពី ៩,៤% ទៅ ១៨% ដែលនឹងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិពី ២% ទៅ ៣,៨%" ។ ចុចទីនេះដើម្បីអានបន្ថែម

## ចិនសន្យាថា នឹងបន្តនាំចូលអង្ករពីកម្ពុជាឱ្យច្រើនជាងមុន និងទិញចេក ស្វាយ ផ្លែមៀន ពីកម្ពុជា ព្រមទាំងគាំទ្រវិស័យអភិវឌ្ឍន៍ផ្សេងទៀត

ប្រភព៖ Cambodian News Channel (CNC)

ក្នុងកិច្ចសន្ទនាតាមប្រព័ន្ធទូរស័ព្ទកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ កន្លងទៅ ប្រធានាធិបតីចិន ស៊ី ជីនពីង បានសន្យានឹងសម្តេចនាយករដ្ឋមន្ត្រីកម្ពុជាថា ភាគីចិននឹងបន្តបង្កើនការនាំចូលអង្ករពីកម្ពុជា ព្រមទាំងទិញផលិតផលសក្តានុពលផ្សេងទៀត រួមមានចេក ស្វាយ និងមៀន ជាដើម ក្នុងគោលដៅជួយកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ លើសពីនេះ ភាគីចិនក៏បានសន្យាជួយពង្រឹងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់កម្ពុជា ព្រមទាំងប្រកាសផ្តល់វ៉ាក់សាំងចំនួន ៥លានដូស ជូនកម្ពុជា ដែលនឹងដឹកមកដល់នៅចុងខែ មីនា នេះ។ ឯកឧត្តម ស៊ី ជីនពីង ក៏បានប្រកាសធ្វើការរួមគ្នាក្នុងការរៀបចំរោងចក្រផលិតវ៉ាក់សាំងនៅកម្ពុជា នាពេលខាងមុខ។ ភាគីចិន ក៏បានសន្យាថានឹងបន្តជំរុញជើងហោះហើររវាងប្រទេសទាំងពីរ ដែលត្រូវបានរំខានដោយមេរោគកូវីដ-១៩ ជិតពីរឆ្នាំកន្លងទៅនេះ។ ចុចទីនេះដើម្បីអានបន្ថែម

[2] បកប្រែក្រៅផ្លូវការ

## Local News

### Samdech Hun Sen and Japan Prime Minister Discuss Potential FTA, Conglomerate Investment, Agriculture Exports

Source: Phnom Penh Post

During the two-day official visit of Japan's Prime Minister to Cambodia from March 20-21, 2022, Cambodia's Prime Minister Samdech Hun Sen has asked his Japanese counterpart Fumio Kishida to consider calling for a study on the potential establishment of a bilateral free trade agreement, convince importers to buy more Cambodian "priority" agricultural products, and encourage prominent Japanese companies to invest in Cambodia. This is the effort of Samdech Prime Minister to further expand bilateral trade and advance economic cooperation with Japan, as well as to secure greater Japanese investment in Cambodia. Furthermore, the two sides agreed to elevate their bilateral strategic partnership to new heights to strengthen and expand bilateral cooperation in fields such as manufacturing, energy, tourism, and other economic sectors, as well as security, communications networks, and intellectual exchanges. The two parties also agreed to combine efforts and turn the Sihanoukville Autonomous Port into a major international trade hub.

### Cambodia's Ministry of Commerce to Finalize Draft Strategy for Maximizing FTAs Benefits[3]

Source: Ministry of Commerce

On 17 March 2022, H.E. PAN Sorarak, Minister of Commerce of Cambodia, led a technical meeting on reviewing and discussing the latest "Draft Strategy for Maximizing Benefits from FTAs" before it will be proceeded to other 15-line ministries for the last reviews and adoption. The draft Strategy, said the Minister, is designed to identify potential products of Cambodia's supremacy poised to enjoy preferences under the existing FTAs. The top ten products examined thus far include rice, casav a, banana, Pailin longan, mango, cashew, meat, natural rubber, pineapple, and pepper. In addition, the Strategy will identify challenges accompanied by respective solutions appropriate in Cambodia's development context. As the CCFTA, RCEP, and CKFTA have been ratified, the Strategy is seen to play a catalytical role in promoting Cambodia's gains from the agreements and beyond. Click here to read more

### RCEP Set to Boost Cambodia Exports by 9-18% Yearly

Source: Khmer Times

Addressing in his remarks in a workshop on "Regional Comprehensive Economic Partnerships: Implications, Challenges and Future Economic Growth for East Asia and ASEAN" on March 14, 2022, Minister of Commerce PAN Sorasak said the latest study by the Economic Research Institute for ASEAN and East Asia (ERIA) revealed that the Kingdom's export is expected an increase by at least 9.4 percent yearly under the RCEP agreement. The figure was adjusted to the figures of 7.2 made in 2014 by the ERIA, he said. "Under the RCEP agreement, Cambodia will see a year's export growth at 9.4 percent to 18 percent, which will contribute to the national economic growth from 2 percent to 3.8 percent," Sorasak said. Click here to read more

### Pledging Rice Import Increase, China to Purchase Banana, Mango, and Longan from Cambodia and Support Other Development Areas[4]

Source: Cambodian News Channel (CNC)

On 18 March 2022's phone call, Chinese President XI Jinping pledged Samdech Techo HUN Sen Prime Minister of Cambodia that China would increase rice import from Cambodia and purchase other potential products, including banana, mango, and longan, from the Kingdom, aimed at helping alleviate the latter's poverty. In addition to trade increase, Chinese counterpart also pledged to enhance Cambodia's physical infrastructures and donate another 5 million doses of Covid-19 vaccine subject to arrive in Phnom Penh in late March. Moreover, China supports Cambodia's construction of Covid-19 vaccine factories and pushes the renormalization of Cambodia-China flight connections following the distractions caused by the virus over the past two years. Click here to read more

[3] [4] Unofficial translations

## ព័ត៌មានសកល[5]

### កិច្ចព្រមព្រៀងអាសិប ចូលជាធរមានក្នុងប្រទេសម៉ាឡេស៊ី

ប្រភព៖ Xinhua

ក្រសួងពាណិជ្ជកម្មរបស់ម៉ាឡេស៊ី បានប្រកាសនៅក្នុងសេចក្តីថ្លែងការណ៍មួយថា កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) បានចូលជាធរមានក្នុងប្រទេសម៉ាឡេស៊ីចាប់តាំងពីថ្ងៃទី១៨ មីនា ឆ្នាំ២០២២ នេះតទៅ។ ក្រសួងបានបន្តថា ប្រទេសនេះត្រូវបានគេរំពឹងថានឹងចំណេញ ២០០លានដុល្លារអាម៉េរិកពីការកើនឡើងនៃការនាំចេញ ដែលធ្វើឱ្យ RCEP ក្លាយជាកិច្ចព្រមព្រៀងដ៏សំខាន់ក្នុងការស្តារឡើងវិញពីផលប៉ះពាល់សេដ្ឋកិច្ច ដែលបណ្តាលមកពីជំងឺរាតត្បាត កូវីដ-១៩៕ *ចុចទីនេះដើម្បីអានបន្ថែម*

### ៥,៨% នៃកំណើនសេដ្ឋកិច្ចប្រទេសអាស៊ីដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ក្នុងឆ្នាំ២០២២ អាចប្រឈមនឹងហានិភ័យដោយសារវិបត្តិសង្គ្រាមនៅអ៊ុយក្រែន

ប្រភព៖ Nikkei Asia

អង្គការសម្រាប់សហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) បានព្រមានថា សង្គ្រាមអ៊ុយក្រែននឹងបន្ថែមហានិភ័យលើអតិផរណា និងខ្សែច្រវាក់ផ្គត់ផ្គង់របស់ប្រទេសតំបន់អាស៊ី ដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ ដែលកំពុងព្យាយាមដោះស្រាយវិបត្តិកូវីដ-១៩។ បើយោងតាមការប៉ាន់ស្មានរបស់អង្គការនេះ ផលិតផលក្នុងស្រុកសរុបរបស់ចិន ឥណ្ឌា និងប្រទេសសមាជិកអាស៊ាន នឹងមានកំណើន ៥,៨% ក្នុងឆ្នាំ ២០២២ ក៏ប៉ុន្តែកំណើននេះអាចនឹងត្រូវបានបង្អាក់ដោយសារហានិភ័យពីវិបត្តិសង្គ្រាមនៅអ៊ុយក្រែន។

សង្គ្រាមនេះ កំពុងតែធ្វើឱ្យមានវិបត្តិសកលមួយចំនួនដូចជា៖ (១) វិបត្តិផ្គត់ផ្គង់សកលធ្ងន់ធ្ងរ ដែលបន្ថែមលើសម្ពាធ និងភាពអាក់អួលអតិផរណាដែលកើតឡើងពីវិបត្តិកូវីដ-១៩ (២) ការឡើងថ្លៃទំនិញ និងវិបត្តិទីផ្សារហិរញ្ញវត្ថុ (៣) ផលប៉ះពាល់អវិជ្ជមានលើការប្រើប្រាស់ឯកជន និងការសម្រេចចិត្តវិនិយោគធុរកិច្ច និង (៤) ភាពធាប់ប្រែប្រួលនៃលំហូមូលធនក្នុងប្រទេសតំបន់អាស៊ី៕ *ចុចទីនេះដើម្បីអានបន្ថែម*

### អ្នកជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុ បានព្យាករថា ប្រាក់យ័នឌីជីថលរបស់ចិន អាចប្រកួតប្រជែងនឹងប្រាក់ដុល្លារអាម៉េរិក ក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ នៅក្នុងទសវត្សរ៍នេះ

ប្រភព៖ CNBC

អ្នកជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុ បានលើកឡើងថា ប្រាក់យ័នឌីជីថលរបស់ប្រទេសចិន ត្រូវបានរៀបចំឡើង ដើម្បីធ្វើការប្រកួតប្រជែងនឹងប្រាក់ដុល្លារអាម៉េរិក ដែលជារូបិយវត្ថុមួយ ត្រូវបានគេប្រើប្រាស់យ៉ាងសកម្មសម្រាប់ការទូទាត់ក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ។ នេះបើយោងតាមការប្រមើមើលរបស់ លោក រិកធាត ធូរិន ជាអ្នកនិពន្ធ និងជាទីប្រឹក្សាផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ។

ប្រទេសចិន បាននិងកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីដាក់ចេញនូវរូបិយបណ្ណឌីជីថលរបស់ធនាគារកណ្តាលរបស់ខ្លួន ដែលបច្ចុប្បន្នកំពុងតែបោះជំហានទៅមុនប្រទេសជាដៃគូនានាជុំវិញពិភពលោក៕

លោក ធូរិន បានលើកឡើងថា ប្រទេសផ្សេងៗទំនងជា កំពុងស្វែងរកប្រព័ន្ធទូទាត់សាច់ប្រាក់ជំនួស ដែលជាផ្នែកមួយនៃ *ការហ្វឹកហាត់ការគ្រប់គ្រងហានិភ័យ* ដើម្បីកាត់បន្ថយការពឹងផ្អែកលើ ប្រាក់ដុល្លារអាម៉េរិក នាពេលបច្ចុប្បន្ន៕ *ចុចទីនេះដើម្បីអានបន្ថែម*

---

[5] បកប្រែក្រៅផ្លូវការ

## អាស៊ាន ដាក់ចេញនូវការចរចាធ្វើឱ្យប្រសើរឡើងនូវ កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ

ប្រភព៖ Xinhua

រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន បានប្រកាសបើកការចរចាសម្រាប់ធ្វើឱ្យប្រសើរឡើង នូវកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ASEAN Trade in Goods Agreement–ATIGA)។ នេះបើយោងតាមសេចក្តីថ្លែងការណ៍ អំឡុងកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី២៨ ដឹកនាំដោយ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងជាប្រធានកិច្ចប្រជុំ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ។

ឯកឧត្តម ប៉ាន សូរស័ក្តិ បានមានប្រសាសន៍ថា រដ្ឋមន្ត្រីអាស៊ាន បានគាំទ្រពេញទំហឹងលើគម្រោងអាទិភាពសេដ្ឋកិច្ចទាំង១៩ ស្នើឡើងដោយកម្ពុជា ក្នុងភាពជាប្រធានអាស៊ានឆ្លាស់វេនឆ្នាំ២០២២ ដែលរួមបញ្ចូលការស្នើឱ្យបើកការចរចារធ្វើឱ្យប្រសើរឡើងនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ដើម្បីធានាថា កិច្ចព្រមព្រៀងនេះ នៅតែមានសារសំខាន់ខ្ពស់ក្នុងការប្រែក្លាយសេដ្ឋកិច្ចតំបន់ទៅជាសេដ្ឋកិច្ចរួម និងមានភាពស្អិតរមួត ពិសេសអំឡុងពេលដែលកំពុងប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ចសកល និងបញ្ហាប្រឈមដែលមិនអាចទាយទុកជាមុនបាននាពេលអនាគត៕ *ចុចទីនេះដើម្បីអានបន្ថែម*

## Global News

### World's Largest Trade Deal RCEP Comes into Effect in Malaysia

Source: Xinhua

The Regional Comprehensive Economic Partnership (RCEP), the world's largest trade deal so far, came into effect in Malaysia from March 18, 2022, the country's trade ministry said in a statement. The country is expected to see a USD 200-million increase in export gains, making the RCEP a vital tool in recovering from the economic disruptions caused by the COVID-19 pandemic, the ministry said… Click here to read more

### Emerging Asia to Grow 5.8% in 2022 but Ukraine Deepens Risks

Source: Nikkei

The Ukraine war adds to inflation and supply chain risks facing an emerging Asia attempting to break out of the COVID-19 slump, the Organization for Economic Cooperation and Development (OECD) warned on March 22, 2022. In a new report, the OECD projects that the GDP of emerging Asia — China, India and ASEAN members — will grow 5.8% this year. However, this growth may be at risk due to a new global uncertainty "Ukraine War". The war is causing the following consequences: (1) strong global supply shock, which adds further to inflationary pressures and disruptions already triggered by the COVID-19 pandemic; (2) the moves in commodity prices and financial; (3) significant negative impact on private consumption and business investment decisions; and (4) an increase in capital flow volatility in Asian countries. Click here to read more

### China's Digital Yuan Could Challenge the Dollar in International Trade This Decade, Fintech Expert Predicts

Source: CNBC

China's digital Yuan is set to challenge the dollar's domination as the currency of choice in international trade settlements, predicts author and financial technology consultant Richard Turrin. China has been ramping up efforts to roll out its central bank digital currency, and is currently far ahead in the space as compared with its global peers. Nations are likely to look for alternative payment systems as part of a "risk management exercise" to reduce their current dependence on the dollar, says Turrin. *Click here to read more*

### ASEAN Launches Negotiations to Upgrade Trade in Goods Agreement

Source: Xinhua

Economic Ministers of the Association of Southeast Asian Nations (ASEAN) Member States have launched negotiations to upgrade the ASEAN Trade in Goods Agreement (ATIGA), the regional bloc said in a statement during the virtual 28th ASEAN Economic Ministers' (AEM) Retreat, which was held under the chairmanship of Cambodia's Commerce Minister Pan Sorasak. The ASEAN ministers also fully supported 19 Priority Economic Deliverables for 2022 proposed by Cambodia, and one of them was the ATIGA Upgrade Negotiations, Pan Sorasak said, as to ensure that the agreement remains highly relevant in transforming the region into a more integrated and cohesive economy, particularly in the face of global economic shocks and volatility. *Click here to read more*

# សង្ខេបគោលនយោបាយ

# ការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅជនបទក្នុងវិស័យកសិកម្មក្នុងប្រទេសកម្ពុជា៖ ការតភ្ជាប់គម្លាតឌីជីថល

*ឯកឧត្តម គាត ពុធសូជារី*[a]
*ឯកឧត្តម ឆែម រិទ្ធី*[b]
*លោកជំទាវ ចម និម្មល*[c]

## សេចក្ដីផ្ដើម

ការសង្ខេបអត្ថបទខ្លីនេះ ធ្វើឡើងក្នុងគោលបំណងផ្ដល់នូវគំនិតផ្តួចផ្តើមប្រកបដោយទស្សនវិស័យសម្រាប់អភិវឌ្ឍ និងអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅទីជនបទ ក្នុងវិស័យកសិកម្មក្នុងប្រទេសកម្ពុជា នាពេលអនាគត។ អត្ថបទនេះផ្ដោតលើនិន្នាការឌីជីថល និងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កាលានុវត្តភាព និងបញ្ហាប្រឈមនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ជារួម និងប្រទេសកម្ពុជាដោយឡែក។ ការស្រាវជ្រាវនេះជាវិភាគទានសម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្តគោលនយោបាយ ដើម្បីជួយសម្រួលក្នុងការតភ្ជាប់គម្លាតឌីជីថលរវាងកសិករនៅជនបទ និងទីផ្សារ តាមរយៈទទួលស្គាល់ចំណុចចាប់ផ្ដើមនៃទម្រង់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅតាមជនបទ និងប្រព័ន្ធអេកូឡូស៊ីឌីជីថល។ អត្ថបទស្រាវជ្រាវសង្ខេបនេះក៏នឹងគាំទ្រដល់គោលនយោបាយ និងផលប័ត្រយុទ្ធសាស្ត្រដែលមានស្រាប់ រួមមាន៖ (i) ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥; (ii) គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥; (iii) យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៩-២០២៣; និង (iv) យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួងពាណិជ្ជកម្មកម្ពុជា ជាដើម។

## ខ្លឹមសារសំខាន់ៗ៖

- ការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិកនៅតាមជនបទ គឺជាក្បាលម៉ាស៊ីនដែលជំរុញកំណើនសេដ្ឋកិច្ច ការងារ និងសហគ្រិនភាពក្នុងវិស័យកសិកម្ម។
- រាជរដ្ឋាភិបាលកម្ពុជាមានគំនិតផ្តួចផ្តើម និងបង្កើតមូលដ្ឋានគ្រឹះលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កសិកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក។ តួអង្គដែលបង្កើតគោលនយោបាយ បាន និងកំពុងប្រឹងប្រែងបន្ត ដើម្បីផ្លាស់ប្តូរប្រទេសកម្ពុជា ទៅជាសេដ្ឋកិច្ចឌីជីថល។

---

[a] ទីប្រឹក្សា និងអ្នកជំនាញគោលនយោបាយ និងទីប្រឹក្សាក្រសួងពាណិជ្ជកម្ម

[b] វិទ្យាស្ថានចក្ខុវិស័យអាស៊ាន

[c] រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- ទោះជាយ៉ាងណា ជាលទ្ធផល បដិវត្តន៍ឌីជីថលនេះ នឹងបង្កើតអ្នកឈ្នះសម្រាប់អ្នកដែលមានជំនាញផ្នែកបច្ចេកវិទ្យាឌីជីថលទំនើប និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលទំនើប និងអ្នកចាញ់ចំពោះអ្នកដែលមានគម្លាតចំណេះផ្នែកឌីជីថល រួមទាំងកង្វះហេដ្ឋារចនាសម្ព័ន្ធផ្នែកឌីជីថល និងក្របខ័ណ្ឌគាំទ្រ ដែលមិនមានលក្ខណៈអំណោយផល ។
- បញ្ហាប្រឈមសំខាន់ៗ ពាក់ព័ន្ធនឹងកង្វះលទ្ធភាពទទួលបានការចូលក្នុងទីផ្សារ ការចំណាយលើជាតុចូលខ្ពស់ ព្រមទាំងលទ្ធភាពនៅមានកម្រិតក្នុងការទទួលបានហិរញ្ញប្បទានផ្សេងៗ បង្កទៅជាខ្សែច្រវាក់តម្លៃកសិកម្មដែលមានលក្ខណៈបែកខ្ញែក។
- ជាទូទៅ តួអង្គសំខាន់ៗនៃខ្សែច្រវាក់តម្លៃនៅតាមជនបទនៃប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថា មានកង្វះខាតផ្នែកចំណេះដឹង និងជំនាញក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឌីជីថល ដើម្បីលក់-ទិញផលិតផល និងទទួលបានព័ត៌មាននិងសេវាបន្ថែមផ្សេងៗ។
- ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងគ្រឹះស្ថានសិក្សា គួរមានវិធានការដូចខាងក្រោម៖
    - គួរមានការស្រាវជ្រាវដើម្បីស្វែងយល់ពីលក្ខណៈសម្បត្តិក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងឌីជីថលនៅតាមជនបទ៖
        i. កំណត់ និងវិភាគនិន្នាការ និងកត្តាជំរុញដែលនាំឱ្យមានការប្រើប្រាស់ឧបករណ៍ឌីជីថលនៅក្នុងប្រព័ន្ធទីផ្សារកសិកម្ម។
        ii. វិភាគទម្រង់ឌីជីថលនៅតាមជនបទ និងឧបសគ្គនានាពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឌីជីថលនៅតាមជនបទ ។
        iii. កំណត់ឧបករណ៍ឌីជីថលក្នុងការទូទាត់តាមប្រព័ន្ធ QR កូដ ប្រើដោយកសិករនៅជនបទ។
        iv. ស្វែងយល់ពីមូលហេតុនៃការមិនទទួលយកការទូទាត់តាមប្រព័ន្ធឌីជីថល និងប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិតដែលមានការក្លែងបន្លំ។
        v. ស្វែងយល់ពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្តរបស់អ្នកប្រើប្រាស់អនឡាញនៅតាមជនបទ។
- ការកសាងសមត្ថភាពលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធឌីជីថល និងអេឡិចត្រូនិកនៅជនបទសម្រាប់កសិករខ្នាតតូច និងសហគ្រាសធុនតូចនិងមធ្យម គួរត្រូវបានជំរុញ។ ដូច្នេះ អត្ថប្រយោជន៍ពីបរិវត្តកម្ម និងសមាហរណកម្មឌីជីថលប្រកបដោយបរិយាប័ន្នអាចកើតឡើង ហើយគម្លាតឌីជីថលរវាងតំបន់ជនបទ និងទីក្រុងនឹងត្រូវបានតភ្ជាប់។

---

## ១. ស្ថានភាពបច្ចេកវិទ្យាឌីជីថលនៅតំបន់អាស៊ីអាគ្នេយ៍

នៅតំបន់អាស៊ីអាគ្នេយ៍ កសិករនៅតាមជនបទបានប្រើប្រាស់ទូរស័ព្ទ និងស្មាតហ្វូនក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះ មានចំនួនច្រើន។ ពួកគេបានទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល ក្នុងការដោះស្រាយបញ្ហាសំខាន់ៗ រួមទាំងបញ្ហាចូលទីផ្សារ បម្រែបម្រួលនិងភាពធន់នៃអាកាសធាតុ ការប្រែប្រួលនៃតម្លៃ លទ្ធភាពតាមដាន និងការចំណាយខ្ពស់នៃធាតុចូលជាដើម (IFAD និង GrowAsia ២០២១)។ បច្ចេកវិទ្យាឌីជីថលបានវិវឌ្ឍជាបីដំណាក់កាលចាប់តាំងពីឆ្នាំ២០១៥។ ដំណាក់កាលទីមួយ ត្រូវបានគេស្គាល់ថាជា "រលកនៃការប្រាស្រ័យទាក់ទងតាមទូរស័ព្ទរបស់កសិករ"។ តួអង្គក្នុងខ្សែច្រវាក់តម្លៃកសិកម្មនេះ បានប្រើទូរស័ព្ទស្មាតហ្វូន ដើម្បីហៅទូរស័ព្ទ ផ្ញើសារ និងជជែកគ្នា ក្នុងកិច្ចការបង្កើតកិច្ចសន្យាលក់-ទិញ កក់ការដឹកជញ្ជូន ព្រមព្រៀងគ្នាលើតម្លៃ និងស្វែងយល់ពីគ្នាទៅវិញទៅមក។ រលកទីពីរ

ដែលគេស្គាល់ថាជា "វលកឌីជីថលក្នុងកសិធុរកិច្ច" បានចាប់ផ្តើមនៅឆ្នាំ២០១៥។ កសិធុរកិច្ចបានទទួលយកឌីជីថលូបនីយកម្មថ្មីដើម្បីតាមដានប្រភពនៃផលិតផលកសិកម្មដែលពួកគេទិញ និងលើកកម្ពស់ប្រសិទ្ធភាពក្នុងចំណោមតួអង្គខ្សែប្រវាក់តម្លៃតូចៗផ្សេងទៀត។ នៅក្នុងទសវត្សរ៍ខាងមុខ វលកទីបីនៃបច្ចេកវិទ្យាថ្មីនឹងត្រូវបានវិវឌ្ឍទៅជាការទូទាត់ឌីជីថលដោយកសិករ វេទិកាពាណិជ្ជកម្មឌីជីថល វេទិកាផ្តល់ប្រាក់កម្ចីឌីជីថល នវានុវត្តន៍ផ្នែករឹងសម្រាប់កសិករខ្នាតតូចៗ ក៏ដូចជាសេវាកម្មប្រឹក្សាកសិករឌីជីថល (IFAD និង GrowAisa ២០២១)។

### រូបភាពទី១៖ អ្នកប្រើប្រាស់អ៊ីនធឺណិតសរុបនៅក្នុងតំបន់អាស៊ីអាគ្នេយ៍




*ប្រភព៖ Google, Temasek, Bain & Company ២០២១*

### រូបភាពទី២៖ សមាហរណកម្មឌីជីថលអាស៊ាន




*ប្រភព៖ Bain & Company Inc. ២០១៨*

ក្នុងរូបភាពទី១ អ្នកប្រើប្រាស់អ៊ីនធឺណិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានកើនឡើងបន្តិចម្តងៗពី ២៦០ លាននាក់ក្នុងឆ្នាំ២០១៥ ដល់ ៤៤០ លាននាក់ (កើន៦៩%) ក្នុងឆ្នាំ២០២១។ សេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានឡើងដល់១០០ប៊ីលានដុល្លារអាមេរិក ជាលើកដំបូងក្នុងឆ្នាំ២០១៩ ហើយវាត្រូវបានគេរំពឹងថានឹងកើនឡើងដល់ ៣០០ ប៊ីលានដុល្លារអាមេរិក ត្រឹមឆ្នាំ២០២៥ (Google, Temasek, Brain & Company ២០២១)។ ស្រដៀងគ្នានេះដែរ រូបភាពទី២ បង្ហាញថាមនុស្សប្រមាណ ៤០ លាននាក់មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត ចាប់តាំងពីឆ្នាំ២០២០ ខណៈដែលសកម្មភាពទិញគ្រឿងទេសផ្សេងៗតាមប្រព័ន្ធអេឡិចត្រូនិក (មានតម្លៃប្រមាណ ៥,១ ប៊ីលានដុល្លារអាមេរិក) បាននិងកំពុងកើនឡើងក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃមេរោគកូវីដ-១៩ (GrowAsia ២០២១)។

ក្នុងរូបភាពទី២ របាយការណ៍ស្រាវជ្រាវមួយរបស់ក្រុមហ៊ុន Bain & Company ក្នុងឆ្នាំ២០១៨ បង្ហាញថា សេដ្ឋកិច្ចឌីជីថលរបស់តំបន់អាស៊ានស្ថិតនៅពីក្រោយប្រទេសដទៃ ដែលមានត្រឹមតែប្រមាណ ៧% នៃផលិតផលក្នុងស្រុកសរុបសកល។ ប្រទេសចិនមាន ២៧% ក្នុងទីផ្សារអឺរ៉ុប ខណៈសហរដ្ឋអាមេរិកមាន ៣៥% នៃផលិតផលក្នុងស្រុកសរុប។ បន្ថែមពីនេះ សមាហរណកម្មសេដ្ឋកិច្ចឌីជីថលអាស៊ាន ត្រូវបានគេរំពឹងថានឹងរួមចំណែកក្នុងការបង្កើនផលិតផលក្នុងស្រុកសរុប ១ ទ្រីលានដុល្លារអាមេរិក ត្រឹមឆ្នាំ២០២៥ (Bain & Company ២០១៨)។ និន្នាការនេះបង្កើតឱ្យមានអ្នកឈ្នះ និងអ្នកចាញ់ក្នុងសេដ្ឋកិច្ចឌីជីថល។

## ២. និន្នាការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅតំបន់អាស៊ីអាគ្នេយ៍

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅជនបទ ក្លាយជាវប្បធម៌ថ្មីមួយ ដែលត្រូវបានអនុវត្តសម្រាប់ទ្រទ្រង់វិស័យសង្គម-សេដ្ឋកិច្ច និងត្រូវបានប្រើប្រាស់ជាអន្តរកម្មរវាងអ្នកផលិត និងពាណិជ្ជករ ដើម្បីលក់ ឬទិញផលិតផល ឱ្យបានប្រសើរលើសពីច្រកទ្វារកសិដ្ឋាន និងទីផ្សារក្នុងស្រុកធម្មតា (Chatterjee ២០១៩)។ សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលប្រើឧបករណ៍ឌីជីថលភ្ជាប់ដោយអ៊ីនធឺណិត ដើម្បីទិញទំនិញឬសេវាកម្ម បាននិងកំពុងរីកលូតលាស់យ៉ាងខ្លាំង។ ប្រទេសឥណ្ឌូនេស៊ី សិង្ហបុរី និងម៉ាឡេស៊ី ទទួលបានចំណាត់ថ្នាក់ខ្ពស់បំផុតក្នុងទីផ្សារទិញទំនិញអនឡាញលើសកលលោក។ នៅ ៥ ឆ្នាំបន្ទាប់ ការលក់តាមប្រព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិកសកល ត្រូវបានគេរំពឹងថានឹងរីកលូតលាស់ឆាប់រហ័ស (Chen and Kimura ២០២០)។

**រូបភាពទី៣៖ ទំហំទីផ្សារនៅតំបន់អាស៊ីអាគ្នេយ៍**




*ប្រភព៖ Google, Temasek, Brain & Company ២០២១*

រូបភាពទី៣ បង្ហាញពីទំហំទីផ្សារតាមវិស័យផ្សេងៗ ដែលក្នុងនោះរួមមានវិស័យចំនួនពីរបន្ថែមដូចជា បច្ចេកវិទ្យាសុខាភិបាល (Healthtech) និងបច្ចេកវិទ្យាអប់រំ (Edtech) ដែលបាននិងកំពុងរីកលូតលាស់ថ្មីៗ។ ជាទ្រឹស្តី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានគេចាត់ថ្នាក់ជាបួនទិសដៅធំៗ៖ ពីធុរកិច្ចទៅអ្នកប្រើប្រាស់ (B2C) ពីធុរកិច្ចទៅធុរកិច្ច (B2B) ពីអ្នកប្រើប្រាស់ទៅអ្នកប្រើប្រាស់ (C2C) និងពីអ្នកប្រើប្រាស់ទៅធុរកិច្ច (C2B)។ យោងតាមការវាយតម្លៃរបស់ស្ថាប័ន UNCTAD ការលក់តាមប្រព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិករវាងធុរកិច្ចទៅធុរកិច្ច និងអ្នកប្រើប្រាស់ទៅធុរកិច្ច បានឡើងដល់កំពូល ដែលមានទឹកប្រាក់សរុបប្រមាណ ២៥,៦ ទ្រីលានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨ ដែលកើនប្រមាណ ៨% ធៀបនឹងឆ្នាំ២០១៧ (UNCTAD ២០២០)។ នៅតំបន់អាស៊ីអាគ្នេយ៍ ការលក់តាមប្រព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិកត្រូវបានគេរំពឹងថា នឹងកើនឡើងទ្វេដងរហូតដល់ ២៥៤ ប៊ីលានដុល្លារអាមេរិក ត្រឹមដើមឆ្នាំ២០២៦ (TECHINASIA ២០២១)។

## ៣. អ្វីទៅជាបញ្ហាប្រឈមចំពោះបច្ចេកវិទ្យាឌីជីថល និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមជនបទក្នុងតំបន់អាស៊ីអាគ្នេយ៍?

បើទោះបីជាមានកាលានុវត្តភាពល្អចំពោះបរិវត្តកម្ម និងសមាហរណកម្មឌីជីថលក្តី ក៏បញ្ហាប្រឈមរួមត្រូវបានគេកំណត់ និងពិភាក្សាក្នុងចំណោមអ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍។ ការវាយតម្លៃរបស់ IFAD និង GrowAsia ក្នុងឆ្នាំ២០២១ បានបង្ហាញថា ជាទូទៅ បញ្ហាចម្បងទីមួយ គឺការខ្វះខាតការវិនិយោគផ្នែកហិរញ្ញវត្ថុ ក្នុងការចាប់ផ្តើមអាជីវកម្មដំបូងរបស់ក្រុមហ៊ុនបច្ចេកវិទ្យាតូចៗ ដែលជាធម្មតាប្រឈមនឹងហានិភ័យវិនិយោគខ្ពស់ក្នុងអាជីវកម្មរបស់ពួកគេ បើទោះបីជាគេអាចបង្កើតផលប៉ះពាល់សំខាន់នានាក្នុងវិស័យបច្ចេវិទ្យាក៏ដោយ។ បញ្ហាចម្បងទីពីរគឺថា រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងកសិករ ប្រហែលជាមិនយល់ដឹងពីតម្លៃបន្ថែមនៃផលិតផលកសិកម្មតាមរយៈបរិវត្តកម្មឌីជីថល។ របាំងទាំងនេះអាចនឹងបង្កទៅជាកង្វះខាតនៃចលករ និងការប្តេជ្ញាចិត្តក្នុងការជំរុញនវានុវត្តន៍ភូមិឌីជីថល។ ដោយឡែក បញ្ហាចម្បងទីបីគឺ រដ្ឋាភិបាលមិនទាន់ត្រៀមខ្លួនរួចរាល់ ដើម្បីស្រូបយកបច្ចេកវិទ្យាកសិកម្មឌីជីថលដោយសារកង្វះខាតនៃអ្នកជំនាញបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងទុនបម្រុង ដែលនាំឱ្យមានភាពអវិជ្ជមានដល់ការស្រូបយកបច្ចេកវិទ្យាទំនើបថ្មីៗ ដូចជា កម្មវិធីឌីជីថល ការទូទាត់ឌីជីថល ការប្រឹក្សាយោបល់កសិករឌីជីថល ឬសេវាវិបុលកម្មឌីជីថល ជាដើម (IFAD and GrowAisa ២០២១)។

រូបភាពទី៤ បង្ហាញថា ជាទូទៅ បញ្ហាប្រឈមរួមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឌីជីថលក្នុងប្រទេសអាស៊ានទាំង៦ រួមមាន បញ្ហាជំនាញនិងលទ្ធភាពនៃការទទួលបានបច្ចេកវិទ្យា បញ្ហាហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅមានកម្រិត និងបញ្ហាថ្នាលឌីជីថលនៅទន់ខ្សោយជាមួយនឹងការតភ្ជាប់អ៊ីនធឺណិតមានកម្រិតទាបខ្លាំងនៅទីជនបទ។ ជាងនេះទៅទៀត គម្លាតឌីជីថលនៅតែមានរវាងតំបន់ទីប្រជុំជន និងជនបទ។ កង្វះខាតខាងជំនាញការបច្ចេកវិទ្យាឌីជីថល និងស្តង់ដារនិយ័តកម្មនឹងកំណត់ពីគន្លងឆាប់រហ័សនៃឌីជីថលូបនីយកម្មក្នុងតំបន់។ ការមិនយល់ដឹងពីចំណេះដឹងឥរិយាបថ និងការអនុវត្តរបស់អតិថិជនអនឡាញ អាចបង្កទៅជាកង្វះខាតនៃការជឿទុកចិត្ត និងភាពជឿជាក់នៃតម្លៃបន្ថែមឌីជីថលចំពោះផលិតផលកសិកម្ម។

## រូបភាពទី៤៖ ឧបសគ្គសំខាន់ៗចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឌីជីថល នៃប្រទេសទាំង០៦ ក្នុងតំបន់អាស៊ាន

| កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី | ថៃ | វៀតណាម |
|---|---|---|---|---|---|
| - កង្វះការយល់ដឹង ពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAP) របស់អ្នកប្រើប្រាស់អនឡាញ (សូមអានបន្តក្នុងរូបភាពទី ៧) | - ការទទួលយកបច្ចេកវិទ្យាមានកម្រិតទាបនៅក្នុងវិស័យឧស្សាហកម្ម<br>- គម្លាតត្រូវបានគេ ឃើញមាននៅក្នុងច្បាប់ស្តីពីការការពារកម្មសិទ្ធិបញ្ញានិងភាពឯកជនផ្នែកទិន្នន័យនិងក្នុងការទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ<br>- កង្វះជំនាញក្នុងបច្ចេកវិទ្យាចុងក្រោយ<br>- ហានិភ័យនៃបទល្មើសអ៊ីនធឺណិត (Ministry of Finance and ADB ២០២០) | - គម្លាតឌីជីថលនៅតែបន្តមាននៅតំបន់ជនបទ<br>- តម្លៃអ៊ីនធឺណិតនៅមានកម្រិតខ្ពស់<br>- រលកអាកាស ដែលមានសមត្ថភាពផ្សព្វផ្សាយ នៅមានកម្រិតនៅឡើយ<br>- គុណភាពសេវាកម្ម និងលទ្ធភាពការប្រើប្រាស់អ៊ីនធឺណិតនៅមិនទាន់ជាក់លាក់<br>- សមត្ថភាពនិយ័តកម្មរបស់អ្នកជំនាញការ នៅមានកម្រិតទាបនៅឡើយ (World Bank ២០១៩) | - ប្រព័ន្ធអេកូឡូស៊ី ពាណិជ្ជកម្មអេឡិចត្រូនិកស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ<br>- ខ្វះទំនុកចិត្តលើការទិញទំនិញតាមអ៊ីនធឺណិត<br>- ខ្វះចំណេះដឹងនិងបុគ្គលិកដែលមានចំណេះដឹងផ្នែកពាណិជ្ជកម្មអេឡិចត្រូនិក<br>- ការគំរាមកំហែងផ្នែកសន្តិសុខអ៊ីនធឺណិត<br>- ការត្រៀមខ្លួនទទួលយកវិស័យឧស្សាហកម្ម៤.០ នៅមានកម្រិត<br>- កង្វះស្តង់ដារ និងបទប្បញ្ញត្តិរបស់អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Salleh et al. ២០២០) | - កង្វះការយល់ដឹងអំពីឥរិយាបថអ្នកប្រើប្រាស់តាមអនឡាញ (អារម្មណ៍និងការលើកទឹកចិត្តដល់ការទិញទំនិញអនឡាញ)<br>- ការមិនទទួលយកការបង់ប្រាក់តាមប្រព័ន្ធឌីជីថល ការប្រើប្រាស់សាច់ប្រាក់គឺនៅតែចាំបាច់<br>- កង្វះហេដ្ឋារចនាសម្ព័ន្ធគ្រប់ដណ្តប់ ទូលំទូលាយ<br>- ការបារម្ភអំពីការជួញដូរក្លែងបន្លំតាមប្រព័ន្ធអនឡាញ (Commonwealth of Australia ២០១៨) | - បញ្ហាប្រឈមធំបំផុតចំពោះវិស័យកសិកម្មគឺ គម្លាតនៃព័ត៌មាន និងទំនាក់ទំនងដែលបណ្តាលឱ្យមានកង្វះប្រសិទ្ធភាពដល់មណ្ឌលនៃខ្សែច្រវាក់តម្លៃកសិកម្ម និងការចំណាយមិនចាំបាច់ (FAO et al.២០២១)។<br>- កង្វះទម្រង់ក្នុងការដឹកជញ្ជូន និងការទូទាត់<br>- ភាពចង្អៀតនៃហេដ្ឋារចនាសម្ព័ន្ធឡូហ្ស៊ីស្ទិកបច្ចុប្បន្ន (Vietnam News ២០១៩) |

*ប្រភព៖ ការបកស្រាយរបស់អ្នកនិពន្ធយកចេញពីអត្ថបទផ្សេងៗ*

## ៤. តើអ្វីទៅជាភាពលានុវត្តភាពរបស់កម្ពុជា?

### ៤.១. ទិដ្ឋភាពឌីជីថល

